# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ បញ្ហាសិទ្ធិមនុស្សនៅកម្ពុជា

website ៖ www.hoksavann.org

ថ្ងៃទី២២ មិថុនា ២០០៩



ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជាបានថ្លែងថា ការប្រើប្រាស់បណ្តឹងស្តីពីបទបរិហារកេរ្តិ៍ និងផ្សាយពត៌មានមិនពិត កំពុងតែរំលោភយ៉ាងធ្ងន់ទៅលើសិទ្ធិសេរីភាពបញ្ចេញមតិនិងប្រជាធិបតេ-យ្យនៅកម្ពុជា ។ សេចក្តីថ្លែងការណ៍នេះបានចេញផ្សាយនៅថ្ងៃទី១៥ មិថុនា ២០០៩បានបន្តថា ចាប់តាំងពីខែមេសាឆ្នាំ២០០៩ មានបណ្តឹងព្រហ្មទណ្ឌដាច់ដោយឡែកៗពីគ្នាយ៉ាងហោចណាស់ចំនួន៦ ដែលចោទទៅលើអ្នកសារពត៌មាន សកម្មជន និងតំណាងរាស្ត្រគណបក្សប្រឆាំង ចោទទៅលើមេធាវីរបស់គណបក្សជំទាស់ និងប្រធានអង្គការក្រៅរដ្ឋាភិបាល ។ បណ្តឹងទាំងប៉ុន្មានកំពុងតែស្ថិតនៅក្នុងការស៊ើបអង្កេត ។ សេចក្តីថ្លែងការណ៍បានសង្កត់ធ្ងន់ថា នៅក្នុងបរិបទដែលតុលាការកម្ពុជាងាយទទួលឥទ្ធិពលពីអំណាចរដ្ឋាភិបាល ទោះជាបណ្តឹងរដ្ឋប្បវេណីក្តី បណ្តឹងព្រហ្មទណ្ឌក្តី បណ្តឹងទាំងនេះគឺជាការគំរាមកំហែងយ៉ាងធ្ងន់ទៅដល់ការអភិវឌ្ឍន៍ប្រជាធិបតេយ្យ ដែលប្រទេ-សកម្ពុជាបានកសាងអស់រយៈពេល១៦ឆ្នាំមកហើយ ។ ការដកអភ័យឯកសិទ្ធិ ឬការគំរាមដកអភ័យឯកសិទ្ធិតំណាងរាស្ត្រ គឺជាការបំភិតបំភ័យសមាជិកសភា និងជាការបំបិទសិទ្ធិជជែកខាងនយោបាយ ។

គួរឲ្យស្តាយ ប្រទេសកម្ពុជាទើបតែបានធ្វើការផ្សះផ្សាជាតិ ក្រោមការ

ឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ក្រោយពេលដែលធ្វើសង្គ្រាមនឹងគ្នា
ជាច្រើនទសវត្សរ៍ គួរតែកុំឲ្យកើតមានអំពើខុសឆ្គងបែបណាមួយតទៅ
ទៀត ដោយលើកយកមេរៀនពីអតីតកាល ។ តាមរបាយការណ៍ពីប្រទេ
សកម្ពុជា ថាប្រព័ន្ធឃោសនាគឺវិទ្យុ ទូរទស្សន៍ និងសារពត៌មានភាគច្រើន
គឺលំអៀងទៅរករដ្ឋាភិបាល ។ បើប្រព័ន្ធឃោសនាណាមានលក្ខណៈប្រ-
ឆាំងរដ្ឋាភិបាល ច្រើនទទួលរងគ្រោះថ្នាក់ ។ ដូចពេលថ្មីៗនេះ និពន្ធនា-
យករបស់សារពត៌មាន«ខ្មែរម្ចាស់ស្រុក» គឺលោកហង្ស-ចក្រា បានត្រូវ
មេធាវីរបស់រដ្ឋាភិបាលប្ដឹងឡើងតុលាការ ដោយចោទសរសេរពាក្យមិន
ពិត ។ តាមរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលថា អ្នកសារពត៌-
មានចំនួន៩នាក់ហើយដែលត្រូវគេលួចសម្លាប់ ។ លោកមឿន-សុន ប្រ
ធានអង្គការមូលនិធិទ្រទ្រង់អរិយធម៌ខ្មែរ បានត្រូវមេធាវីរបស់រដ្ឋាភិបាល
ប្ដឹងដែរ ដោយចោទថានិយាយពាក្យមិនពិត ទាក់ទងនឹងការដាក់អំពូល
ភ្លើងនៅប្រាសាទអង្គរវត្ត ។ គួរឲ្យឆ្ងល់ បើនិយាយពាក្យមិនពិត គ្រាន់តែ
ឲ្យកែតម្រូវទៅជាការចប់ ម៉េចក៏ចាំប្ដឹង ។ គួរតែឲ្យប្រជាពលរដ្ឋជួយប-
ញ្ចេញយោបល់ក្នុងការស្ថាបនាជាតិ ។ បញ្ហាមួយទៀត ជាបញ្ហាចម្លែក
ជាងគេក្នុងពិភពលោក គឺបញ្ហាអ្នកស្រីមួរ-សុខហួរតំណាងរាស្ត្រមណ្ឌ-
លខេត្តកំពត ដែលត្រូវគេប្រមាថ ផ្ទុយទៅវិញអ្នកស្រីបានត្រូវគេចោទ
ប្រកាន់ថាបរិហារកេរ្តិ៍គេទៅវិញ ហើយអ្នកស្រីបានត្រូវគេរៀបចំដកអភ័-
យឯកសិទ្ធិទៀតផង ។ មិនតែប៉ុណ្ណោះ មេធាវីរបស់អ្នកស្រី ក៏ត្រូវគេប្ដឹង
ដែរ ។ ការឈ្លោះគ្នាយកឈ្នះចាញ់ជារឿងធម្មតា ប៉ុន្តែសំខាន់នៅលើតុ-
លាការ ។ តើតុលាការខ្មែរប្រកាន់គោលជំហរអព្យាក្រិត្យ និងឯករាជ្យឬ
ទេ ? ច្បាស់ណាស់ អន្តរជាតិតែងចោទថា តុលាការខ្មែរតែងលំអៀងទៅ
រកអ្នកកាន់អំណាច ។ ដល់ពេលហើយ លោកតុលាការគួរប្រកាន់គោល
ជំហរយុត្តិធម៌ គួរអាណិតអាសូរដល់អ្នកស្លូតត្រង់ កុំសាងអំពើបាប ។
តាមផ្លូវព្រះពុទ្ធសាសនា អ្នកមួលបង្កាច់គេមិនបានសុខទេ ។ ពាក្យខ្មែរ
មួយឃ្លាពោលថា «បំបាត់ភ្នែកជញ្ជីងទាំងថ្លៃក្រឡែត» ។ មួយឃ្លាទៀត
ពោលថា «ចោររួចខ្លួន ម្ចាស់ទ្រព្យជាប់គុក» គួរពិចារណាពាក្យនេះ ។

លោកស្រីឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាបានថ្លែងក្នុងឱកាសនៃកម្មវិធីប្រគុំតន្ត្រីបាតដៃស្អាតស្អំ កាលពីថ្ងៃទី៣០ ឧសភា ២០០៩ថា ដោយផ្អែកទៅលើការសិក្សាជាច្រើនបានបង្ហាញថា អំពើពុករលួយបានធ្វើឲ្យកម្ពុជាបាត់បង់ចំណូលថវិកាជាតិ រហូតដល់ទៅ៥០០លានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ។ បើតួលេខនេះពិតឬមិនពិតទាំងស្រុងក៏ដោយ ក៏គួររដ្ឋាភិបាលខំព្យាយាមកំចាត់អំពើពុករលួយបន្តិចម្តងៗ ជាជាងមានប្រតិកម្មថាឲ្យគេដោយពាក្យពុំសមរម្យណាមួយ ព្រោះអ្នកថានោះ សុទ្ធតែចង់ឲ្យប្រទេសកម្ពុជាបានលូតលាស់ចំរើន ចេញពីការក្រីក្រ ។ របាយការណ៍ប្រចាំឆ្នាំរបស់សហរដ្ឋអាមេរិកបានចោទថា រដ្ឋាភិបាលខ្មែរបានធ្វើឲ្យចំរើនតិចតួចណាស់ ក្នុងការរត់ពន្ធមនុស្សទៅប្រទេសថៃ ទៅម៉ាឡេស៊ី ទៅចិនតៃវ៉ាន់ ឲ្យធ្វើពលកម្ម ឲ្យធ្វើស្រីពេស្យា ដែលមានការពាក់ព័ន្ធទៅលើអ្នករាជការខ្មែរផង ។ បើគេថាដូច្នេះ ត្រូវតែចាត់ការបំបាត់អំពើជំនួញខុសច្បាប់នេះ ឲ្យមានប្រសិទ្ធិភាពថែមទៀត ។ គួរឲ្យរន្ធត់បញ្ហាមួយទៀត អាជ្ញាធរខ្មែរបានដេញប្រជាពលរដ្ឋពីលំនៅរបស់គេ ដើម្បីយកដីទៅអភិវឌ្ឍន៍ ។ មានកន្លែងខ្លះបានបាញ់ប្រជាពលរដ្ឋដែលមិនព្រមចេញបានត្រូវរបួស មានខ្លះបានស្លាប់ មានកន្លែងខ្លះចាប់ប្រជាពលរដ្ឋដាក់គុកថែមទៀត ។ ការអភិវឌ្ឍន៍ទំនងជាប្រជាពលរដ្ឋមិនប្រឆាំងទេ ប៉ុន្តែបញ្ហាមួយគឺសំណង ។ នៅសហរដ្ឋអាមេរិកនិងកាណាដា បើរដ្ឋត្រូវការដីកន្លែងណាមួយរបស់ឯកជន រដ្ឋមិនត្រឹមតែឲ្យតម្លៃស្មើនឹងតម្លៃទីផ្សារទេ គឺឲ្យតម្លៃលើស ដើម្បីឲ្យប្រជាពលរដ្ឋសុខចិត្ត ។ តើអាជ្ញាធរខ្មែរបែបណាដែរ ? បើធ្វើមិនត្រឹមត្រូវ ជាការរំលោភសិទ្ធិប្រជាពលរដ្ឋក្នុងការតាំងទីលំនៅ ។ តាមពត៌មានមួយថា ប៉ូលិសបានចាប់ឃុំមនុស្សម្នាក់ ក្រោយមកមនុស្សនោះបានត្រូវស្លាប់ ដែលអ្នកចាប់នោះនិយាយថា ស្លាប់ដោយចងកខ្លួនឯង ។ តើគួរឲ្យជឿឬទេ មនុស្សនោះនៅក្នុងកណ្តាប់ដៃរបស់ខ្លួន តើទៅចងកដូចម្តេចកើត ? បើចងកពិតប្រាកដមែន ហេតុដូចម្តេចបានជាមិនឲ្យគេពិនិត្យធ្វើកោសល្យវិច័យ ហេតុដូចម្តេចបានជាយកទៅបូជាបំបិទកស្តុតាង ? តើអ្នកដែលខ្លួនចាប់គ្រាន់តែមានសេចក្តី

សង្ស័យ មានវាយដំគេរហូតដល់ស្លាប់ពិតមែនឬទេ ? ប្រជាពលរដ្ឋរង
គ្រោះមិនដែលទទួលបានយុត្តិធម៌ឡើយ ។

អ្នកដឹកនាំខ្មែរនិយាយថា បើមានបាតុកម្មប្រឆាំងរដ្ឋាភិបាល គាត់នឹង
ដឹកនាំអ្នកគាំទ្ររដ្ឋាភិបាលប្រឆាំងនឹងបាតុកម្មវិញ ។ អស្ចារ្យណាស់ ក្នុង
ពិភពលោកប្រហែលមានតែអ្នកដឹកនាំខ្មែរម្នាក់នេះទេ ដែលមានគំនិតដូ-
ច្នេះ ។ របបប្រជាធិបតេយ្យពុំបានមានន័យថា បើមានប្រជាពលរដ្ឋប្រឆាំ
ងនឹងរដ្ឋាភិបាល រដ្ឋាភិបាលកេណ្ឌប្រជាពលរដ្ឋឲ្យប្រឆាំងបាតុកម្មវិញយ៉ា
ងនេះទេ តែគេយកខ្លឹមសារនៃបាតុកម្មនោះមកដោះស្រាយ ។ ឧបមាថា
រាល់តែពេលបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាល រដ្ឋាភិបាលមិនដោះស្រាយ
តែបែរជាបង្កើតបាតុកម្មប្រឆាំងតបវិញ តើប្រទេសខ្មែរទៅជាបែបម៉េច
ទៅវិញ ? រដ្ឋាភិបាលដឹកនាំប្រជាពលរដ្ឋ តែបែរជាប្រឆាំងនឹងប្រជាពល
រដ្ឋរបស់ខ្លួនទៅវិញបែបនេះ ។ តើចាត់ទុកជាអ្នកទទួលខុសត្រូវឬទេ ? គំ
និតបែបនេះ គេឃើញមាននៅក្នុងរបបកុម្មុយនិស្តនិងរបបផ្តាច់ការទេ
របបប្រជាធិបតេយ្យពិតប្រាកដមិនក្លែងក្លាយ មិនមានគំនិតបែបនេះទេ ។
ឧទាហរណ៍ជាក់ស្តែង ប្រធានាធិបតីសហរដ្ឋអាមេរិក, ប្រធានាធិបតីបារាំ
ង, នាយករដ្ឋមន្ត្រីកាណាដា, នាយករដ្ឋមន្ត្រីអូស្ត្រាលីជាដើម ដែលគេកា
ន់របបប្រជាធិបតេយ្យពិតប្រាកដ រាល់ពេលប្រជាពលរដ្ឋធ្វើបាតុកម្ម កូដ
កម្ម គេតែងលើកយកមកដោះស្រាយ គេពុំដែលមានគំនិតបង្កើតបាតុកម្ម
ប្រឆាំងបាតុកម្មវិញដូចនេះឡើយ ។ គំនិតបែបនេះ ធ្វើឲ្យខូចកិត្តិយសខ្លួន
ឯង ហើយធ្វើឲ្យប្រជាពលរដ្ឋខ្មែរខ្មាស់គេពេញពិភពលោក ព្រោះតែអ្នក
ដឹកនាំខ្មែរមានគំនិតបែបនេះ ។ បង្កើតបាតុកម្មប្រឆាំងបាតុកម្មរបស់រដ្ឋាភិ
បាល ពុំមែនបន្ទាមុតយកបន្ទាដោះទេ តែមានន័យផ្ទុយទៅវិញថា បន្ទា
មុតយកបន្ទាមួយទៀតចាក់ឲ្យមុតថែម ឬដំបៅឈឺយកឈើចាក់ថែម
ព្រោះកាលណាមានបាតុកម្មតបតគ្នា នាំឲ្យមានបញ្ហាវឹកវរក្នុងប្រទេស ដែ
លមានលក្ខណៈរដ្ឋាភិបាលបង្កើតអសន្តិសុខក្នុងប្រទេសដោយខ្លួនឯង ។
រដ្ឋាភិបាលអាចយល់ថា បើបង្ក្រាបបាតុកម្មឲ្យខ្លាំងរហូតប្រើហិង្សា ប្រជា
ពលរដ្ឋនឹងបាក់ស្បាតលែងហ៊ានធ្វើបាតុកម្ម ។ យើងយល់ថា ស្ងប់បាន

តែផ្លូវកាយ ចំណែកផ្លូវចិត្តមិនស្ងប់ទេ ដូចជាបាតុកម្មឆ្នាំ១៩៩៧ ។ ព្រះពុទ្ធសាសនាសំដែងយ៉ាងច្បាស់ថា អ្នកដឹកនាំពូកែ គឺអ្នកដឹកនាំដែលធ្វើឲ្យគេគ្រប់គ្នាស្ងប់ផ្លូវចិត្ត ។ តាមភាសាធម្មតាថា ធ្វើឲ្យគេអស់ចិត្ត ស្រឡាញ់ ហើយគោរពទាំងទីចំពោះមុខទាំងទីកំបាំងមុខ ។ អ្នកដឹកនាំណាដែលធ្វើឲ្យប្រជាពលរដ្ឋក្តៅក្រហាយ នាំឲ្យមានពៀរទៅខាងមុខ ហើយអំណាចនោះមានភាពរង្គោះរង្គើ ។ អ្នកដឹកនាំអាចមានយោបល់ផ្ទុយទៅវិញថា ប្រជាពលរដ្ឋភាគច្រើនលើសលប់គាំទ្រ មានតែពួកអគតិមួយក្តាប់ទេដែលប្រឆាំង ។ មួយក្តាប់តូចមួយក្តាប់ធំក៏ដោយវាមិនសំខាន់ទេ តែសំខាន់ស្ថិតនៅលើខ្លួនឯងសាងឲ្យល្អ តែសាងអាក្រក់ហើយគ្មានអ្វីទប់បានឡើយ ។ នេះជាច្បាប់កម្មផលរបស់ព្រះពុទ្ធសាសនា ។ កុំខ្លាចប្រជាពលរដ្ឋបញ្ចេញមតិនិងឆន្ទៈរបស់ខ្លួន តាមរយៈធ្វើបាតុកម្មនិងកូដកម្ម ។ តាមពិតសកម្មភាពទាំងនេះជាការជួយរដ្ឋាភិបាលវិញទេ ដើម្បីឲ្យរដ្ឋាភិបាលពិនិត្យមើលខ្លួនឯងមានខុសឆ្គង និងខ្វះចន្លោះកន្លែងណាដែលមិនបានបំពេញ បានជាគំនិតកែឲ្យល្អឡើងវិញ ។ ចំពោះបញ្ហាបន្តិចបន្តួចបច្ចុប្បន្ននេះ ជារឿងតូចតាចកុំឲ្យពួតផ្តុំជាធំ យកល្អអ្នកដឹកនាំខ្មែរគួរសុំទោសជាផ្លូវការចំពោះកំហុសដែលប្រមាថអ្នកស្រីមួរ-សុខហួរ ។ គ្មានថោកអីនឹងដៃ ថ្ងៃអីនឹងមាត់ទេ ។ បើធ្វើដូច្នេះបាន គេកោតសរសើរ ហើយគេគោរពថែមទៀត ។ បើនៅតែដកអភ័យឯកសិទ្ធិពីអ្នកស្រីមួរ-សុខហួរ ហើយតុលាការកាត់សេចក្តីបែបណាមួយ នោះជាការសាងអំពើបាបធ្ងន់ណាស់ ។ អ្វីទាំងអស់កុំថាគេល្ងង់ គេស្តាប់ទៅយល់ហេតុយល់ផលបាន ។ អ្នកស្រីមួរ-សុខហួរអាចហៅគាត់ទៅឆ្លើយបំភ្លឺក្នុងតុលាការបាន មិនជាការចាំបាច់ដែលត្រូវដកអភ័យឯកសិទ្ធិទេ ។ ដកអភ័យឯកសិទ្ធិលុះតែមានទោសឧក្រិដ្ឋជាក់ស្តែង មិនមានតំណែងនិងទីលំនៅពិតប្រាកដ ។ ចំពោះបងប្អូនតុលាការ បងប្អូនសភាជាតិ គួរមានសម្បជញ្ញៈឯករាជ្យខ្លួនឯងហើយ មិនត្រូវលំអៀងព្រោះស្រឡាញ់ព្រោះស្អប់ព្រោះភ័យខ្លាចព្រោះល្ងង់មិនដឹងការពិតឡើយ ។ តុលាការបានព្យួរទុកមិនដោះស្រាយចំពោះសំណុំរឿងរបស់អ្នកស្រីមួរ-សុខហួរដែលជាអ្នករងគ្រោះ តែបែរជាដោះស្រាយនូវ

ពាក្យបណ្ដឹងតបអ្នកប្រមាថគេវិញ ។ តុលាការសោងអំពើបាបធ្ងន់ណាស់ ខ្មៅទៅជាស សទៅជាខ្មៅ ។ សព្វថ្ងៃនេះ គេមិនខ្វាចទេរឿងប្ដឹងប្ដល់គ្នា រកយុត្តិធម៌ ប៉ុន្តែគេខ្វាចតុលាការរបៀបនេះ ។ ប្រទេសណាមួយដែលតុលាការមិនយុត្តិធម៌ហើយ ប្រជាពលរដ្ឋនៃប្រទេសនោះនឹងស្គាល់នូវសេចក្ដីសោយសោករងទុក្ខវេទនាដោយអយុត្តិធម៌ជានិច្ច ពីអ្នកមានអំណាច និងពីអ្នកមានប្រាក់កាស ។ ពីដើមមានលួចសម្លាប់គ្នារកមុខមិនឃើញ ឥឡូវនេះប្រែផែនការថ្មី គឺយកតុលាការជាឧបករណ៍សំរាប់កំចាត់គ្នា ។ នៅប្រទេសប្រជាធិបតេយ្យ អ្នកមានអំណាចថ្នាក់ណាក៏ដោយ បើប្រព្រឹត្តខុសធ្ងន់ហើយ ប៉ូលិសចាប់ដាក់ខ្នោះយកឡើងតុលាការដូចប្រជាពលរដ្ឋធម្មតា គឺស្មើគ្នាចំពោះមុខច្បាប់ ។

ចំពោះបញ្ហាខ្មែរកម្ពុជាក្រោម បើរដ្ឋាភិបាលខ្មែរមិនហ៊ានជួយទេ ដោយយកវៀតណាមជាមិត្តរាប់ម៉ឺនឆ្នាំនោះ ក៏កុំយកជើងរាទឹកនិងធ្វើបាបខ្មែរកម្ពុជាក្រោមថែមទៀត ដូចករណីចាប់ផ្សឹកព្រះសង្ឃទឹម-សាខន ដែលជាពលរដ្ឋរបស់ខ្លួន ប្រគល់ឲ្យគេយកទៅកាត់ទោសនៅប្រទេសវៀត-ណាមជាដើម ។

ប្រទេសកម្ពុជាបើនៅតែរករឿងនឹងគ្នា យកគ្នាជាសត្រូវ ប្រើល្បិចកំចាត់គ្នា ដោយមិនអនុវត្តតាមច្បាប់ឲ្យបានត្រឹមត្រូវ បើសភាមិនស្ថិតនៅក្នុងជំហរប្រយោជន៍ជាតិ តុលាការមិនឯករាជ្យមិនយុត្តិធម៌ បើប្រព័ន្ធឃោសនាមិនមានតុល្យភាព បើកងទ័ពមិនស្ថិតនៅជាកងទ័ពជាតិ បើប៉ូលិសនិងកងរាជអាវុធហត្ថមិនស្ថិតនៅជាអព្យាក្រឹត្យ នោះប្រទេសកម្ពុជាមិនមានការស្ងប់ តែងតែមានការវិវាទគ្នាជានិច្ច ហើយសេចក្ដីសុខចំរើនពុំអាចកើតឡើងបានឡើយ ។ ឯទឹកដីដែលរួមតូចនេះ នឹងរួមតូចតទៅទៀត ដោយការឈ្លានពានពីប្រទេសជិតខាង ដោយខ្មែរចេះតែបែកបាក់គ្នា ។ ដើម្បីឲ្យមានឯកភាពជាតិ មានតែនាំគ្នាគោរពច្បាប់ទម្លាប់របស់ប្រទេស តាមរបបប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។ បើមានបញ្ហាជាតិកើតឡើង ត្រូវនាំគ្នាដោះស្រាយដោយសន្តិវិធី ជៀសវាងអំពើហឹង្សាលួចសម្លាប់គ្នា ។ បើខ្មែររួបរួមគ្នាមានឯកភាពជាតិហើយ បរទេសជាពិសេស

ប្រទេសជិតខាង ដែលធ្លាប់តែរំលោភយកទឹកដីខ្មែរ នឹងកោតញញើតពុំខានឡើយ ។

យើងបានឆ្លៀតពេលពីសកម្មភាពព្រះពុទ្ធសាសនា មកនិយាយអំពីសិទ្ធិមនុស្សនៅប្រទេសកម្ពុជានេះ ដោយក្នុងរយៈពេលប៉ុន្មានខែនេះឮពត៌មានខ្លះពីប្រទេសកម្ពុជា ពត៌មានខ្លះគួរឲ្យរន្ធត់ ពត៌មានខ្លះគួរឲ្យអស់សំណើច ពត៌មានខ្លះអយុត្តិធម៌ខ្លាំងពេកអត់មិនបាន ក៏ផ្តល់យោបល់ខ្លះដល់ប្រជាពលរដ្ឋខ្មែរ ជាពិសេសអ្នកដឹកនាំខ្មែរបច្ចុប្បន្នយកទៅពិចារណា ដោយសូមកុំធ្វើអ្វីដែលនាំឲ្យខ្មែរបែកបាក់គ្នា ធ្វើឲ្យខ្មែរខ្សោយកម្លាំងចំពោះមុខសត្រូវ ដែលកំពុងឈ្លានពានទឹកដីខ្មែរ ជាពិសេសចោរសៀមដែលកំពុងចង់បានព្រះវិហាររបស់ខ្មែរជាដើម ។

❄ ❄

❄